# រំលឹកមេរៀនចិត្តត្រៀមចូលបកិណ្ណក

មើលកិច្ច ១៤  មានជវនកិច្ច

កាមជវនកិច្ច កាមាវចរចិត្តដែលធ្វើជវនកិច្ច (ធ្វើការសោយអារម្មណ៍)
ជវនកិច្ច មានន័យថា ស្ទុះទៅកាន់អារម្មណ៍ឬសេពសោយអារម្មណ៍។ គឺជាចិត្តដែលមានកំលាំងជាងគេ មានសន្ទុះដូចសេះស្ទុះទៅ ចិត្តដ៏ទៃមិនអាចញ៉ាំងដៃជើងឲ្យកំរើក ឲ្យសំលាប់គេបានទេ។ ការសំរេចឲ្យទៅជានិយាយ ទៅជាលើកដៃជើងធ្វើអ្វីមួយ ក៏មកពីពួកចិត្តណាដែលធ្វើជវនកិច្ចនឹងឯង។ ដូចជា ទស្សនកិច្ច មានកំលាំងខ្សោយ មិនអាចញ៉ាំងដៃញ៉ាំងជើងឲ្យកំរើកបានទេ។ មូលហេតុ ព្រោះ ចក្ខុវិញ្ញាណដែលឃើញរូបារម្មណ៍ កើតឡើងតែ១ខណៈ តែជវនកិច្ចកើតឡើងយ៉ាងហោចក៏ ៧ ខណៈជាប់ៗគ្នា។

អប្បនាជវន ចិត្តស្ងប់ ដើម្បីឡើងអង្គឈាន

__១. តើចិត្តចែកជាប៉ុន្មានប្រភេទធំអ្វីខ្លះ? និមួយៗមានចិត្តប៉ុន្មានដួង?__
ចិត្តចែកជា៤ ប្រភេទធំ មានៈ
- កាមាវចរចិត្ត  ៥៤ ដួង
- រូបាវចរចិត្ត   ១៥ ដួង
- អរូបាវចរចិត្ត  ១២ ដួង
- លោកុត្តរចិត្ត  ៨ ដួង ដោយសង្ខេប ឬ ៤០ ដួងដោយពិស្តារ

__២. តើចិត្តមានវេទនាប៉ុន្មាន? អ្វីខ្លះ?__
ចិត្តមាន៣ វេទនា សុខ ទុក្ខ និង ឧបេក្ខា
ឬ ចិត្តមាន ៥ វេទនា ដោយការសោយអារម្មណ៍ជាធំ សុខវេទនា សោមនស្សវេទនា ទុក្ខវេទនា ទោមនស្សវេទនា ឧបេក្ខាវេទនា។

__៣. តើអកុសលចិត្តមានវេទនាប៉ុន្មាន? អ្វីខ្លះ?__
អកុសលចិត្តមាន ៣វេទនា គឺ ៖ សោមនស្សវេទនា ទោមនស្សវេទនា និង ឧបេក្ខាវេទនា។

__៤. តើអមោហហេតុកើតក្នុងចិត្តប៉ុន្មាន?__
ចិត្តទាំងអស់៨៩ ហើយជាអមោហហេតុ ជាញាណសម្បយុត្ត មានៈ
មហាកុសលចិត្ត ៤ ដួង មហាវិបាកចិត្ត ៤ ដួង មហាកិរិយាចិត្ត ៤ ដួង រូបាវចរចិត្ត ១៥ ដួង អរូបាវចរចិត្ត ១២ ដួង និង លោកុត្តរចិត្ត ៨ ដួង។

សរុប មាន ៤៧ ដួង។ (សូម បងៗ ជួយពិនិត្យថាត្រូវឬទេ?)

__៥. តើអសោភណចិត្តប៉ុន្មានមានហេតុ១? អ្វីខ្លះ?__
អសោភណចិត្តទាំងអស់មាន ៣០ ដួង ចែកជាពីរះ អកុសលចិត្ត ១២ ដួង និង អហេតុកចិត្ត ១៨ ដួង។
តែសំនួរសួរពីហេតុចឹងចិត្ត១៨ខាងចុងនេះមិនចាត់ចូលទេ
ហេតុនេះមានអសោភណចិត្តដែលមានហេតុ១ ចំនួន ២ ដួង គឺ មោហមូលចិត្ត ២ ដួង។

សរុប មាន ២ ដួង។

<u>៦. តើកាមាវចរចិត្តប៉ុន្មានដួងជាសោមនស្សវេទនា?</u>
កាមាវចរចិត្តទាំងអស់មាន ៥៤ ដួង ហើយចិត្តទាំងនោះ ដែលមានសោមនស្សវេទនា៖ លោភមូលចិត្ត ៤ ដួង អហេតុកកុសលវិបាក ដួងទី ៨ អហេតុកកិរិយាចិត្ត ដួងទី ៣ មហាកុសលចិត្ត ៤ ដួង មហាវិបាកចិត្ត ៤ ដួង មហាកិរិយាចិត្ត ៤ ដួង។

សរុបមាន ១៨ ដួង។

<u>៧. តើឈានចិត្តប៉ុន្មានជាសោមនស្សវេទនា?</u>
ឈានចិត្តមិនមានសោមនស្សវេទនាទេ។

សរុប 0 ដួង។

<u>៨. តើកាមជវនមានចិត្តអ្វីខ្លះ?</u>
កាមជវនកិច្ច កាមាវចរចិត្តដែលធ្វើជវនកិច្ច (ធ្វើការសោយអារម្មណ៍)

<u>៩. តើចិត្តអ្វីខ្លះជាអប្បនាជវន?</u>
អប្បនាជវន ចិត្តស្ងប់ ដើម្បីឡើងអង្គឈាន

មាន រូបាវចរចិត្ត ១៥ ដួង និង អរូបាវចរចិត្ត ១២ ដួង។

សរុបមាន ២៧ ដួង។

<u>១០. តើអសោភណចិត្តមានសោមនស្សវេទនាប៉ុន្មានដួង?</u>
៦ ដួង គឺអកុសល ៤ និង អហេតុកកុសលវិបាកចិត្ត ដួងទី ៧ និង អហេតុកកិរិយាចិត្ត ដួង ទី ៣

<u>១១. តើអសោភណវិបាក មានចិត្តប៉ុន្មានដួងជាឧបេក្ខាវេទនា?</u>
សរុបមាន ១២ ដួង។

<u>១២. តើកាមាវចរចិត្តប៉ុន្មានដួងដែលមិនមានហេតុប្រកប?</u>
សរុបមាន ១៨ ដួង។

<u>១៣. តើកាមាវចិត្តប៉ុន្មានដួងធ្វើកិច្ចបាន ៤?</u>
មាន មហាវិបាក៨ ដួង ធ្វើកិច្ច ៤ បដិសន្ធិកិច្ច ភវង្គកិច្ច តទាលម្ពណកិច្ច ចុតិកិច្ច

<u>១៤. តើកាមាវចិត្តប៉ុន្មានដួងធ្វើកិច្ចបាន ២?</u>

មាន អហេតុកកុសលវិបាកចិត្ត ដួងទី ៧ ធ្វើកិច្ច ២ គឺ សន្តីរណកិច្ច និង តទាលម្ពណកិច្ច

សន្តីរណកិច្ច ៖ ពិចារណាអារម្មណ៍
តទាលម្ពណកិច្ច៖ ទទួលអារម្មណ៍ ពីជវន

<u>១៥. តើអសោភណចិត្តមានចិត្តប៉ុន្មានធ្វើកិច្ចបានតែ១?</u>

សរុប ២៦ ដួង  ដក អកុសលវិបាកចិត្ត ដួងទី ៧ អហេតុកកុសលវិបាកចិត្ត ដួងទី ៧ និង ៨
អហេតុកកិរិយាចិត្ត ដួងទី ២

**១៦. តើសោភណចិត្តប៉ុន្មានដួងធ្វើជវនកិច្ច?**
មហាកុសល ៨ ដួង
មហាកិរិយា ៨ ដួង
កុសលមហគ្គតចិត្ត ៩ ដួង
កិរិយាមហគ្គតចិត្ត ៩ ដួង
លោកុត្តរចិត្ត ៨ ដួង

សរុប មាន ៤២ ដួង។

**១៧. តើកាមាវចរចិត្តប៉ុន្មានដែលកើតក្រៅទ្វារ?**

អកុសលវិបាកចិត្ត ដួងទី ៧
អហេតុកកុសលវិបាកចិត្ត ដួងទី ៨
មហាវិបាកចិត្ត ៨ ដួង

សរុប មាន ២៣ ដួង។

**១៨. តើកាមាវចិត្តប៉ុន្មានដួងកើតបានតែទ្វារ១?**

អកុសលវិបាកចិត្ត ដួងទី ១ ដល់ ដួងទី ៥
អហេតុកកុសលវិបាកចិត្ត ដួងទី ១ ដល់ ដួងទី ៥

សរុប មាន ១០ ដួង។

**១៩. តើកាមាវចរចិត្តប៉ុន្មានដួងកើតបានតែទ្វារ ៥?**
អកុសលវិបាកចិត្ត ដួងទី ៦
អហេតុកកុសលវិបាកចិត្ត ដួងទី ៦
អហេតុកកិរិយាចិត្ត ដួងទី ១

សរុប មាន ១៣ ដួង។

# សំណួរចិត្តបរមត្ថវគ្គ២ ភាគ១ ០២មេសា២០២៤៖

១- តើចិត្តមានលក្ខណៈដូចម្តេច?

២- តើចិត្តមានប៉ុន្មានដួងដោយសង្ខេប? ប៉ុន្មានដួងដោយពិស្តារ?
ចិត្តមាន ៨៩ ដួងដោយសង្ខេប ឬ ១២១ ដួង ដោយពិស្តារ។

៣- តើចិត្តចែកជាប៉ុន្មានប្រភេទធំៗ? អ្វីខ្លះ?
ចិត្តចែកជា ៤ ប្រភេទធំៗ មាន ៖
ក. កាមាវចរចិត្ត ៥៤ ដួង
ខ. រូបាវចរចិត្ត ១៥ ដួង
គ. អរូបាវចរចិត្ត ១២ ដួង
ឃ. លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង

៤- តើកាមាវចរចិត្ត មានន័យដូចម្ដេច? មានប៉ុន្មានដួង?
កាមាវចរចិត្ត មានន័យថា ចិត្តដែលត្រាច់ទៅរកកាម អារម្មណ៍ ដ៏ច្រើន។
កាមាវចរចិត្ត មាន ៥៤ ដួង។

៥- តើរូបាវចរចិត្ត មានន័យដូចម្ដេច? មានប៉ុន្មានដួង?
រូបាវចរចិត្ត មានន័យថា ចិត្តដែលត្រាច់ទៅរករូប ជាអារម្មណ៍(១០ កសិណ)មាន បឋវីកសិណជាដើម ដ៏ច្រើន។
រូបាវចរចិត្ត មាន ១៥ ដួង។

៦- តើអរូបាវចរចិត្ត មានន័យដូចម្ដេច? មានប៉ុន្មានដួង?
អរូបាវចរចិត្ត មានន័យថា ចិត្តដែលត្រាច់ទៅរកអរូប ជាអារម្មណ៍(មានកសិណុគ្ឃាដិមាកាស ជាដើម) ដ៏ច្រើន។
អរូបាវចរចិត្ត មាន ១២ ដួង។

៧- តើលោកុត្តរចិត្ត មានន័យដូចម្ដេច? មានប៉ុន្មានដួង?
លោកុត្តរចិត្ត មានន័យថា ចិត្តដែលមាននិព្វានជាអារម្មណ៍ ឬ ចិត្តដែលដឹងអារម្មណ៍ជានិព្វាន។
លោកកុត្តរចិត្ត មាន ៨ ដួង ឬ ៤០ ដួង។

៨- តើកាមាវចរចិត្ត ចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?
កាមាវចរចិត្ត ចែកជា ២ ប្រភេទ គឺ
ក. អសោភណចិត្ត ៣០ ដួង
ខ. សោភណចិត្ត ២៤ ដួង

៩- ដូចម្ដេចហៅថា អសោភណចិត្ត?
អសោភណចិត្ត ជាចិត្តដែលមិនមានសោភណចេតសិកប្រកបជាមួយ។

១០- ដូចម្ដេចហៅថា សោភណចិត្ត?
សោភណចិត្ត ជាចិត្តដែលមានសោភណចេតសិកប្រកបជាមួយ។

១១- តើអសោភណចិត្ត ចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?
អសោភណចិត្ត ចែកជា២ ប្រភេទ គឺ៖
ក. អកុសលចិត្ត ១២ ដួង
ខ. អហេតុកចិត្ត ១៨ ដួង

១២- ដូចម្ដេចហៅថា អកុសលចិត្ត?
អកុសលចិត្ត ជាចិត្តបាប ចិត្តអាក្រក់។

១៣- ដូចម្តេចហៅថា អហេតុកចិត្ត?
អហេតុកចិត្ត ជាចិត្តដែលមិនមានហេតុណាមួយក្នុងចំណោមហេតុទាំង៦ប្រកបជាមួយ។

១៤- តើអកុសលចិត្ត ចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?
អកុសលចិត្ត ចែកជា៣ប្រភេទ គឺះ
ក. លោភមូលចិត្ត
ខ. ទោសមូលចិត្ត
គ. មោហមូលចិត្ត

១៥- ដូចម្តេចហៅថា លោភមូលចិត្ត?
លោភមូលចិត្ត ជាចិត្តដែលមានឫស ឬ មូល ឬ ហេតុជាលោភៈ។

១៦- ដូចម្តេចហៅថា ទោសមូលចិត្ត?
ទោសមូលចិត្ត ជាចិត្តដែលមានឫស ឬ មូល ឬ ហេតុជាទោសៈ។

១៧- ដូចម្តេចហៅថា មោហមូលចិត្ត?
មោហមូលចិត្ត ជាចិត្តដែលមានឫស ឬ មូល ឬ ហេតុជាមោហៈ។

១៨- តើលោភមូលចិត្ត មានប៉ុន្មានដួង?
លោភមូលចិត្ត មាន ៨ ដួង។

១៩- តើលោភមូលចិត្តដួងទី១ មានឈ្មោះជាបាលី ថាដូចម្តេចខ្លះ?
សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

២០- តើលោភមូលចិត្តដួងទី១ មានឈ្មោះ ជាសម្រាយ ថាដូចម្តេចខ្លះ?
លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ មានកំលាំងក្លៀវក្លា មិនមានការបបួលដឹកនាំ។

២១- តើលោភមូលចិត្តដួងទី១ មានប៉ុន្មានចំនុចគួរកត់សម្គាល់? ចូររៀបរាប់ចំនុចនីមួយៗ ជាភាសាបាលីនិងសម្រាយផង?
លោភមូលចិត្តដួងទី១ មាន ៣ ចនុចគួរកត់សម្គាល់។
ក. សោមនស្សសហគតំ ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា
ខ. ទិដ្ឋិគតសម្បយុត្តំ ប្រកបដោយការយល់ខុស មិច្ឆាទិដ្ឋិ
គ. អសង្ខារិកំ មានកំលាំងក្លៀវក្លា មិនមានការបបួលដឹកនាំ

២២- តើលោភមូលចិត្តដួងទី១ មានចេតសិកប្រកបប៉ុន្មាន? អ្វីខ្លះ?
លោភមូលចិត្តដួងទី១ មាន ចេតសិក ១៩ ប្រកបជាមួយ។ មាន
ក. សោមនស្សសហគតំ អញ្ញាសមានាចេតសិក ១៣
សព្វចិត្តសាធារណចេតសិក ៧ ផស្សៈ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ និង មនសិការៈ
បកិណ្ណកចេតសិក ៦ វិតក្កៈ វិចារៈ អធិមោក្ខ វិរិយៈ បីតិ ឆន្ទៈ
ខ. ទិដ្ឋិគតសម្បយុត្តំ លោតិកៈ លោភៈ និង ទិដ្ឋិ (រៀវ មានៈ)
គ. អសង្ខារិកំ

អកុសលចិត្តតែងតែមាន មោចតុក: ៤ ប្រកបជាមួយ។ មាន មោហ: អហិរិក អនោត្តប្ប: និង ឧទ្ធច្ច: ។

២៣- ដូចម្តេចហៅថា ចិត្តុប្បាទ?
ចិត្តុប្បាទ គឺជាសម្បយុត្តិធម៌ មាន ចិត្ត និង ចេតសិក កើតរួមគ្នា។

២៤- តើចិត្តុប្បាទនៃលោភមូលចិត្តដួងទី១ មានសភាវធម៌ប៉ុន្មានយ៉ាង? អ្វីខ្លះ?
ចិត្តុប្បាទនៃលោភមូលចិត្តដួងទី១ មានសភាវធម៌ ២ យ៉ាង គឺ ចិត្ត និង ចេតសិក។

២៥- តើលោភមូលចិត្តដួងទី១ មានវេទនាប៉ុន្មានប្រភេទប្រកបជាមួយ? អ្វីខ្លះ?
២៦- តើសោមនស្សវេទនា អង្គធម៌បានដល់អ្វី?
២៧- ខណ:សប្បាយរីករាយដោយបានឃើញកូនជាទីស្រលាញ់
ព្រមដោយយល់ថាកូននេះជាកូនខ្លួនឯង តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
២៨- ខណ:សប្បាយរីករាយក្នុងការស្តាប់ចម្រៀង ព្រមដោយយល់ថាខ្លួនឯងជាអ្នកឮ
តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
២៩- ខណ:សប្បាយរីករាយក្នុងការបានហិតក្លិនកូនង៉ែត ព្រមដោយយល់ថាខ្លួនឯងជាអ្នកដឹងក្លិននោះ
តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
៣០- ខណ:សប្បាយរីករាយក្នុងការញាំសម្លរឆ្ងាញ់ ព្រមដោយយល់ថាខ្លួនឯងជាអ្នកដឹងរសនោះ
តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
៣១- ខណ:សប្បាយរីករាយ ក្នុងពេលគេគក់ច្របាច់ឱ្យថ្នមៗ ព្រមដោយយល់ថាខ្លួនឯងជាអ្នកស្រួល
តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
៣២- បន្ទាប់ពីសម្លាប់សត្វ ក៏សប្បាយរីករាយ ព្រោះបានសាច់សត្វមកញាំ
ព្រមដោយយល់ថាមិនមានបាបទេ ក្នុងការសម្លាប់សត្វនោះ តើខណ:នេះចិត្តណាប្រាកដឡើង?
ចូរញែក?
៣៣- ខណ:សប្បាយរីករាយ ក្នុងមុខរបរលួចគេ ព្រមដោយយល់ថាមិនមានបាបទេ
តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
៣៤- ខណ:សប្បាយរីករាយក្នុងការប្រព្រឹត្តកាមជាមួយប្រពន្ធគេ ព្រមដោយយល់ថាមិនមានបាបទេ
តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
៣៥- ខណ:សប្បាយរីករាយ ក្នុងការកុហកក្មេង ព្រមដោយយល់ថាមិនមានបាបទេ តើខណ:នេះ
ចិត្តណាប្រាកដឡើង? ចូរញែក?
៣៦- ខណ:សប្បាយរីករាយ ក្នុងការបន់ស្រន់សុំសុខពីព្រះពុទ្ធ
ព្រមដោយយល់ថាព្រះពុទ្ធជាអ្នកឱ្យសុខដល់ខ្លួនឯង តើខណ:នេះចិត្តណាប្រាកដឡើង? ចូញែក?
៣៧- ខណ:សប្បាយរីករាយ ក្នុងការរកស៊ីមានបាន ព្រមដោយយល់ថាខ្លួនឯងជាអ្នកបានលុយនោះ
តើខណ:នេះ ចិត្តណាប្រាកដឡើង? ចូរញែក?
៣៨- ខណ:សប្បាយរីករាយ ក្នុងការបានឡើងបុណ្យស័ក្តិ ព្រមដោយយល់ថា
ខ្លួនឯងជាអ្នកបានឡើងបុណ្យស័ក្តិ តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
៣៩- ខណ:សប្បាយរីករាយ ក្នុងការឃើញពុទ្ធបដិមារ ព្រមដោយយល់ថា ខ្លួនឯងជាអ្នកឃើញ
តើខណ:នេះចិត្តណាប្រាកដឡើង? ចូរញែក?
៤០- ខណ:សប្បាយរីករាយ ក្នុងការធ្វើសំណួរនិងចម្លើយត្រូវ ព្រមដោយយល់ថាខ្លួនឯងជាអ្នកធ្វើ
តើខណ:នេះ ចិត្តណាប្រាកដឡើង? ចូរញែក?

# សំណួររំលឹកការចែកលោភមូលចិត្តដោយន័យផ្សេងៗ ១ដល់៦ ភាគ១០ ១៩មេសា២០២៤

១- តើចិត្ត៨៩ដួងឬ១២១ដួង មានជាតិប៉ុន្មានយ៉ាង? អ្វីខ្លះ?
២- តើលោភមូលចិត្តទាំង៨ដួង ចាត់ជាជាតិណា?
៣- តើភូមិរបស់ចិត្តមានប៉ុន្មាន? អ្វីខ្លះ?
៤- តើលោភមូលចិត្តទាំង៨ដួង ស្ថិតក្នុងភូមិចិត្តមួយណា?
៥- តើភូមិសត្វមានប៉ុន្មានភូមិ? អ្វីខ្លះ?
៦- តើលោភមូលចិត្តទាំង៨ដួង អាចកើតក្នុងភូមិសត្វបានប៉ុន្មានភូមិ?
៧- តើអសញ្ញីសត្តាជាភូមិមានខន្ធប៉ុន្មាន? គឺខន្ធអ្វី?
៨- តើវេទនាចែកជាប៉ុន្មានក្នុងការសោយអារម្មណ៍? ហើយប៉ុន្មានជាធំក្នុងការសោយអារម្មណ៍? អ្វីខ្លះ?
៩- តើលោភមូលចិត្ត៨ដួង មានវេទនាប៉ុន្មានយ៉ាង? អ្វីខ្លះ?
១០- តើលោភមូលចិត្ត៨ដួងជាហេតុឬហេតុ?
១១- តើក្នុងដួងនីមួយៗនៃលោភមូលចិត្តទាំង៨ដួងមានហេតុប៉ុន្មាន? អ្វីខ្លះ?
១២- តើចិត្តដែលមានហេតុ២កើតរួមជាមួយ ហៅថាចិត្តអ្វី?
១៣- តើក្នុងលោភមូលចិត្ត៨ដួង ចិត្តដែលកើតដោយមិនមានការបបួលដឹកនាំមានប៉ុន្មានដួង? ដួងណាខ្លះ?
១៤- តើក្នុងលោភមូលចិត្ត៨ដួង ចិត្តដែលកើតដោយការបបួលដឹកនាំមានប៉ុន្មានដួង? ដួងណាខ្លះ?
១៥- តើក្នុងលោភមូលចិត្ត៨ដួង ចិត្តដែលមានមិច្ឆាទិដ្ឋិប្រកបជាមួយ មានប៉ុន្មានដួង? ដួងណាខ្លះ?
១៦- តើក្នុងលោភមូលចិត្ត៨ដួង ចិត្តដែលមិនមានមិច្ឆាទិដ្ឋិប្រកបជាមួយ មានប៉ុន្មានដួង? ដួងណាខ្លះ?

# សំណួរការចែកលោភមូលចិត្តដោយន័យផ្សេងៗ ៧-១៤ ភាគ១១ ២៧មេសា២០២៤

១- បើចែកដោយសោភណ: តើចិត្ត៨៩ដួងឬ១២១ដួងចែកជាប៉ុន្មានសោភណ:? អ្វីខ្លះ?
២- តើលោភមូលចិត្តស្ថិតក្នុងសោភណមួយណា? ហេតុអ្វី?
៣- ដោយឈាន តើចិត្ត៨៩ដួងឬ១២១ដួង ចែកជាប៉ុន្មានឈាន? អ្វីខ្លះ?
៤- តើអឈានចិត្ត បានដល់ចិត្តប៉ុន្មានប្រភេទ? អ្វីខ្លះ?
៥- តើឈានចិត្តបានដល់ចិត្តប៉ុន្មានប្រភេទ? អ្វីខ្លះ?
៦- តើអកុសលឈាន មានន័យដូចម្តេច?
៧- តើលោភមូលចិត្តចាត់ជាឈានចិត្តឬអឈានចិត្ត? ហេតុអ្វី?
៨- បើចែកជាលោកិយ: តើចិត្ត៨៩ដួងឬ១២១ដួង ចែកជាប៉ុន្មានលោកិយ:? អ្វីខ្លះ?
៩- តើលោកិយចិត្ត មានន័យដូចម្តេច?
១០- តើលោកិយចិត្ត បានដល់ចិត្តប៉ុន្មានប្រភេទ? អ្វីខ្លះ?
១១- តើលោកុត្តរចិត្ត មានន័យដូចម្តេច?
១២- តើលោកុត្តរចិត្ត បានដល់ចិត្តប៉ុន្មានប្រភេទ? អ្វីខ្លះ?

១៣- តើលោភមូលចិត្ត ជាលោកិយចិត្តឬលោកុត្តរចិត្ត? ហេតុអ្វី?
១៤- ដោយកិច្ច តើចិត្ត៨៩ដួងឬ១២១ដួង មានកិច្ចប៉ុន្មាន?
១៥- តើលោភមូលចិត្តធ្វើកិច្ចអ្វី?
១៦- តើជវនកិច្ច មានន័យដូចម្ដេច?
១៧- តើអារម្មណ៍ មានន័យដូចម្ដេច?
១៨- តើអារម្មណ៍មានប៉ុន្មានប្រភេទ? អ្វីខ្លះ?
១៩- តើលោភមូលចិត្តដឹងអារម្មណ៍បានប៉ុន្មាន? អ្វីខ្លះ?
២០- តើទ្វារក្នុងបរមត្ថធម៌ មានន័យដូចម្ដេច?
២១- តើទ្វារមានប៉ុន្មាន? អ្វីខ្លះ?
២២- តើលោភមូលចិត្ត ប្រព្រឹត្តតាមទ្វារបានប៉ុន្មាន? អ្វីខ្លះ?
២៣- តើលោភមូលចិត្ត ដែលប្រព្រឹត្តតាមចក្ខុទ្វារ ដឹងអារម្មណ៍បានប៉ុន្មាន? អ្វីខ្លះ?
២៤- តើលោភមូលចិត្ត ដែលប្រព្រឹត្តតាមសោតទ្វារ ដឹងអារម្មណ៍បានប៉ុន្មាន? អ្វីខ្លះ?
២៥- តើលោភមូលចិត្ត ដែលប្រព្រឹត្តតាមឃានទ្វារ ដឹងអារម្មណ៍បានប៉ុន្មាន? អ្វីខ្លះ?
២៦- តើលោភមូលចិត្ត ដែលប្រព្រឹត្តតាមជិវ្ហាទ្វារ ដឹងអារម្មណ៍បានប៉ុន្មាន? អ្វីខ្លះ?
២៧- តើលោភមូលចិត្ត ដែលប្រព្រឹត្តតាមកាយទ្វារ ដឹងអារម្មណ៍បានប៉ុន្មាន? អ្វីខ្លះ?
២៨- តើលោភមូលចិត្ត ដែលប្រព្រឹត្តតាមមនោទ្វារ ដឹងអារម្មណ៍បានប៉ុន្មាន? អ្វីខ្លះ?
២៩- តើលោភមូលចិត្ត អាចប្រព្រឹត្តទៅនៅក្រៅទ្វារបានដែរឬទេ? ហេតុអ្វី?
៣០- តើវត្ថុក្នុងបរមត្ថធម៌ មានន័យដូចម្ដេច?
៣១- តើវត្ថុមានប៉ុន្មាន? អ្វីខ្លះ?
៣២- តើចក្ខុវត្ថុ ជាទីកើតនៃចិត្តប៉ុន្មានដួង?
៣៣- តើសោតវត្ថុ ជាទីកើតនៃចិត្តប៉ុន្មានដួង?
៣៤- តើឃានវត្ថុ ជាទីកើតនៃចិត្តប៉ុន្មានដួង?
៣៥- តើជិវ្ហាវត្ថុ ជាទីកើតនៃចិត្តប៉ុន្មានដួង?
៣៦- តើកាយវត្ថុ ជាទីកើតនៃចិត្តប៉ុន្មានដួង?
៣៧- តើហទយវត្ថុ ជាទីកើតនៃចិត្តប៉ុន្មានដួង?
៣៨- តើលោភមូលចិត្តអាស្រ័យវត្ថុបានប៉ុន្មាន? អ្វីខ្លះ?
៣៩- តើវិញ្ញាណធាតុ មានន័យដូចម្ដេច?
៤០- តើចិត្ត៨៩ដួងឬ១២១ដួង ចែកជាប៉ុន្មានវិញ្ញាណធាតុ? អ្វីខ្លះ?
៤១- តើចក្ខុវិញ្ញាណធាតុ ជាធាតុនៃចិត្តប៉ុន្មានដួង?
៤២- តើសោតវិញ្ញាណធាតុ ជាធាតុនៃចិត្តប៉ុន្មានដួង?
៤៣- តើឃានវិញ្ញាណធាតុ ជាធាតុនៃចិត្តប៉ុន្មានដួង?
៤៤- តើជិវ្ហាវិញ្ញាណធាតុ ជាធាតុនៃចិត្តប៉ុន្មានដួង?
៤៥- តើកាយវិញ្ញាណធាតុ ជាធាតុនៃចិត្តប៉ុន្មានដួង?
៤៦- តើមនោធាតុ ជាធាតុនៃចិត្តប៉ុន្មានដួង?
៤៧- តើមនោវិញ្ញាណធាតុ ជាធាតុនៃចិត្តប៉ុន្មានដួង?
៤៨- តើលោភមូលចិត្តចាត់ជាវិញ្ញាណធាតុណាមួយក្នុងចំណោមវិញ្ញាណធាតុទាំង៧?
៤៩- តើលោភមូលចិត្ត អាចប្រព្រឹត្តទៅក្នុងចតុវោការភូមិបានដែរឬទេ? ហើយអាស្រ័យវត្ថុដែរឬទេ? ហេតុអ្វី?
៥០- តើលោភមូលចិត្ត អាចប្រព្រឹត្តទៅក្នុងឯកវោការភូមិបានដែរឬទេ? ហេតុអ្វី?

ចូរពន្យល់

រូបជ្ឈានកន្លងអង្គឈាន
អរូបជ្ឈានកន្លងអារម្មណ៍
តើមានន័យយ៉ាងណា?

ខ្ញុំសូមសាកល្បងបកស្រាយ។ ត្រូវឬខុស សូមជួយកែលំអរផង ទាន។

ពាក្យឈានកន្លងក្នុងបរិបទនេះមានន័យថា កន្លងចោល រុញចោល ឬ លះចេញ

ដោយពិចារណាឃើញទោសរបស់អង្គឈាន ព្រោះវានៅក្បែរនីវរណធម៌នៅឡើយ
រូបជ្ឈានបានលះចេញ  នូវអង្គឈានដែលគ្រោតគ្រាតនោះចេញ
ហើយបន្ថោនចិត្តបរិកម្មក្នុងកសិណនិមិត្ត ដើម្បីតោងយកអារម្មណ៍ដែលប្រណិតជាង
ដើម្បីបានឈានថ្នាក់ខ្ពស់ជាង។
ឧទាហរណ៍ តតិយជ្ឈាន (រូបាវចរកុសលចិត្តដួងទី៣) បានលះ បីតិ
ដោយពិចារណាសំលឹងឃើញទោសរបស់បីតិ ហើយបន្ថោនចិត្តបរិកម្មក្នុងកសិណនិមិត្តណាមួយនៃ
កសិណទាំង ១០ ដែលយកមកប្រើតាំងពីបឋមឈាន  រហូតសំរេចចូលចតុត្ថជ្ឈាន។

ចំនែក អរូបជ្ឈានកន្លងអារម្មណ៍ ក៏ប្រហាក់ប្រហែលនឹងរូបឈានដែរ។
ដើម្បីឲ្យការបកស្រាយមានភាពងាយស្រួល ខ្ញុំសូមយក នេវសញ្ញានាសញ្ញាយតនកុសលចិត្តុំ(
អរូបឈានទី៤ ) ជាឧទាហរណ៍។

ដើម្បីបានចូលអរូបឈានទី៤  ព្រះយោគាវចរត្រូវរុញចោលនូវអារម្មណ៍ឈ្មោះថា
នត្ថិភាវបញ្ញត្តិជាមុនសិន រួចក៏ទាញតោង អាកិញ្ចញ្ញាយតនឈានជាអារម្មណ៍វិញ
ដោយធ្វើមនសិការៈលើ អារម្មណ៍នេះ ថា"ស្ងប់ៗ" ដូច្នេះឯង។